# កិច្ចប្រជុំបូកសរុប លទ្ធផលការងារមាត្រាសាស្ត្រឆ មាសទី១ ឆ្នាំ២០១៦ និងលើកទិសដៅការងារបន្ត




នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំកិច្ចប្រជុំបូកសរុប លទ្ធផលការងារមាត្រាសាស្ត្រឆមាសទី១ ឆ្នាំ២០១៦ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្ត នៅសាលប្រជុំនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

ថ្លែងក្នុងពិធីនេះ លោកជំទាវ ពៅ វរលក្សណ៍ ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានលើកឡើងថា វិស័យមាត្រាសាស្ត្រជាតិ របស់កម្ពុជា គឺមានមូលដ្ឋានគ្រឹះ បម្រើដល់សេវាសាធារណៈ ធានាឲ្យការធ្វើជំនួញ និងការប្រកបអាជីវកម្ម មានភាពយុត្តិធម៌និងត្រឹមត្រូវ បង្កឲ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ មានភាពសុចរិត និងការធានាដល់ផលប្រយោជន៍ រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ លើផលិតផលទំនិញ ការធានាឲ្យកាន់តែប្រសើរឡើង នូវគុណភាពទំនិញ ផលិតផលសេវាកម្ម និងការគ្រប់គ្រង ការកំណត់អត្តសញ្ញាណ និងការលុបបំបាត់របាំង បច្ចេកទេស ដើម្បីធ្វើឲ្យមានជំនឿទុកចិត្ត លើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ក្នុងសកម្មភាពធុរកិច្ច និងវិស័យផ្សេងៗទៀត។

តាមការឱ្យដឹងពីមន្ត្រីជំនាញ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានការចង្អុលបង្ហាញ និងណែនាំ ពីលោកទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម វិស័យមាត្រាសាស្ត្រ ត្រូវបានយកចិត្តទុកដាក់ និងអភិវឌ្ឍគួរឱ្យកត់សម្គាល់។ ជាក់ស្តែង បន្ទាប់ពីបានបង្កើត មន្ត្រីនគបាលយុត្តិធម៌រួចមកនេះ ក្រុមមន្ត្រីនគរបាលយុត្តិធម៌ ដែលជាមន្ត្រី នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចុះអនុវត្តលើកិច្ចការជាប្រចាំ ក្នុងការត្រួតពិនិត្យ លើខ្នាតរង្វាស់រង្វាល់ទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យការធ្វើជំនួញ និងការប្រកបអាជីវកម្ម មានភាពស្មោះត្រង់ និងយុត្តធម៌ ក្នុងការផ្តល់សេវា និងផលិតផលជូន ដល់អ្នកប្រើប្រាស់ត្រឹមត្រូវ ទៅតាមបរិមាណដែលអ្នកលក់ និងអ្នកទិញបានព្រមព្រៀងគ្នា។

ជាការគួរឱ្យកត់សម្គាល់ផងដែរ នៅរយៈពេលចុងក្រោយនេះ យើងសង្កេតឃើញថា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំឱ្យមាន ជញ្ជីងយុត្តិធម៌ដាក់ នៅតាមទីផ្សារនានា នៅស្ទើរពាសពេញផ្ទៃប្រទេស ដែលជញ្ជីងទាំងអស់នោះ ត្រូវបានដាក់ជូនអាជីវករ ក៏ដូចជាអ្នកប្រើប្រាស់ ដែលមានការមន្ទិលសង្ស័យ ចំពោះបរិមាណ ដែលខ្លួនបាន លក់ ឬជាវ គឺអាចប្រើប្រាស់ ជញ្ជីងយុត្តិធម៌នេះបាន ដោយមិនមានការយកកំរៃអ្វីទាំងអស់ ហើយជញ្ជីញនោះទៀតសោត គឺអាចធានាបាននូវភាពសុក្រឹត និងយុត្តិធម៌ ទាំងចំពោះអ្នកលក់ និងអ្នកទិញ ព្រោះជញ្ជីងទាំងនោះត្រូវបាន គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវសុក្រឹតភាពនៃទម្ងន់ ដោយមន្ត្រីជំនាញ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត។

គួរបញ្ជាក់ផងដែរថា ដើម្បីជម្រុញឲ្យមានការទទួលស្គាល់ បទដ្ឋានមាត្រាសាស្ត្រ ក្នុងលំដាប់ខ្នាតអន្តរជាតិ កម្ពុជាបានចូលជាសមាជិក នៃអង្គការមាត្រាសាស្ត្រអន្តរជាតិនានា ជាច្រើន ហើយសមាជិកភាព ទាំងនេះ នឹងជួយពង្រីកវិសាលភាព នៃវិស័យមាត្រាសាស្ត្រឲ្យកាន់តែរឹងមាំ និងផ្តល់នូវទំនុកចិត្តកាន់តែខ្លាំង សម្រាប់ទាំងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់។












39
MINISTRY OF INDUSTRY & HANDICRAFT